# មាតាបិតាក៏រាប់ផងដែរ

## ជួយកូនរបស់លោកអ្នកនៅក្នុង - ការវាស់ចំណុះ និងដុំ(ម៉ាស)

ការពិសោធន៍ដើមដំបូងរបស់កុមារជាមួយនឹងការវាស់ នឹងកើតមានឡើងដោយពឹងផ្អែកទៅលើការដែលគេឃ្លាំមើលលោកអ្នក ក្នុងភាពជាមាតាបិតារបស់គេ។ ការឃ្លាំមើលម្ដាយ ឬឪពុកវាស់ និងចាក់ចូលគ្រឿងម្ហូបដើម្បីធ្វើរូបមន្តម្ហូបអាហារ ឬថ្លឹងរបស់នៅតាមហាងលក់ផ្លែឈើ ជាញឹកញយនឹងក្លាយទៅជាផ្នែកនៃការលេងរបស់គេនៅថ្ងៃបន្ទាប់។

### តើកុមាររៀនចេះវាស់ចំណុះ និងដុំ(ម៉ាស) ដោយបែបណា?

ជាដំបូងកុមាររៀនចេះបង្កើតនូវការដឹងយល់អំពីរង្វាស់ តាមរយៈការប្រៀបធៀបរបស់។ គេអាចចាប់លើកប្រដាប់លេងពីរ ហើយនិយាយថាមួយធ្ងន់ជាង ឬស្រាលជាងប្រដាប់លេងមួយទៀត ឬមើលទៅកែវទឹកពីរ ហើយនិយាយថាកែវមួយមានទឹកច្រើនជាងកែវមួយទៀត។ បន្ទាប់ភ្លាមនោះមកគេក៏ចាប់ផ្ដើមប្រៀបធៀបរបស់ច្រើនជាងពីរ។

កុមារត្រូវការលេងជាមួយសម្ភារ: និងធុងផ្សេងៗដើម្បីចាក់បំពេញ ខ្ចប់ និងចាក់ចូល មុននឹងគេអាចចាប់ផ្ដើមប្រើរង្វាស់ *ត្រឹមត្រូវ* ដូចជាគីឡូម៉ែត្រ និងក្រាម។ គេត្រូវការដឹងអំពីរបៀបរៀបចំទុកដាក់របស់ជាមួយគ្នា ដើម្បីបំពេញធុង ហើយថារបស់មួយណាល្អជាងគេដើម្បីខ្ចប់។





Curriculum K–12 Directorate, © NSW Department of Education

# មាតាបិតាក៏រាប់ផងដែរ

## តើលោកអ្នកអាចធ្វើអ្វីបានខ្លះនៅផ្ទះ?

- ឲ្យកូនរបស់លោកអ្នកនូវពែងទំហំផ្សេងៗគ្នា ឬធុងប្លាស្ទិកធំមួយដើម្បីលេងនៅក្នុងអាងងូតទឹក។ លើកទឹកចិត្តឲ្យកូនរបស់លោកអ្នកប៉ាន់ស្មានថាតើត្រូវការទឹកចំនួនប៉ុន្មានពែងដើម្បីចាក់បំពេញធុងនោះ។
- និយាយអំពីចំនួនគ្រឿងមុខម្ហូបនីមួយៗប៉ុន្មានពែង ឬប៉ុន្មានស្លាបព្រាដែលត្រូវប្រើនៅក្នុងរូបមន្តម្ហូប ពេលណាលោកអ្នកដាំស្លក្នុងពេលជាមួយគ្នា។
- លើកទឹកចិត្តឲ្យកូនរបស់លោកអ្នកទុកដាក់ប្រដាប់ និងសៀវទៅលេងរបស់គេ។ និយាយអំពីរបៀបដែលរបស់ទាំងនោះនឹងអាចរៀបត្រូវទុកដាក់ល្អ ដោយយោងទៅលើរបៀបដែលកូនរបស់លោកអ្នកទុកដាក់របស់ទាំងនោះ។
- ចាក់ពូនគំនរដីខ្សាច់ចេញពីធុងប្លាស្ទិកធំ ដើម្បីឲ្យកូនរបស់លោកអ្នកអាចចាក់ដីខ្សាច់បំពេញធុងធំហំផ្សេងៗ។ កន្ត្រង ចំពួយទឹកសំរាប់ស្រោចដំណាំ ស្លាបព្រា និងដបប្លាស្ទិក បំពង់ដាក់ទស្សនាវដ្ដីចាស់ ដីឡារ ទាំងនេះគឺជាសម្ភារៈដ៏មានប្រយោជន៍សំរាប់លេងជាមួយដីខ្សាច់។
- រាប់ចំនួនពែងនៃទំផាស្ដាក្រៀម ឬពោតលីងប៉ុន្មានដែលត្រូវការ ដើម្បីបំពេញក្នុងចានធំមួយ។
- និយាយអំពីចំនួនប៉ុន្មានដែលអ្នកអាចចាប់កាន់នៅក្នុងដៃរបស់លោកអ្នក។ ប្រៀបធៀបចំនួនគ្រាប់កូនឃ្លី ឬដុំគ្រួសប៉ុន្មានដែលលោកអ្នកអាចចាប់កាន់ ទៅនឹងចំនួនដែលកូនរបស់លោកអ្នកអាចចាប់កាន់។
- ប្រមូលប្រអប់ដែលមានទំហំផ្សេងៗគ្នា។ លើកទឹកចិត្តកូនរបស់លោកអ្នកឲ្យបានដឹងថាតើគេអាចដាក់ប្រអប់មួយចូលទៅក្នុងប្រអប់មួយទៀតឬទេ។ និយាយអំពីប្រអប់មួយណាដែលត្រូវចាប់ផ្ដើមប្រើមុនគេ ហើយតើមកពីហេតុអ្វី។
- បំពេញប្រអប់ដាក់ស្បែកជើងជាមួយដុំរបស់ ដោយដាក់រៀបមួយស្រទាប់ម្ដងៗ។ រាប់ចំនួនដុំដែលត្រូវការដើម្បីដាក់រៀបមួយស្រទាប់ រួចហើយដាក់រៀបស្រទាប់មួយចំនួនទៀត។


Curriculum K–12 Directorate, © NSW Department of Education

# មាតាបិតាក៏រាប់ផងដែរ

- "ការថ្លឹងដោយដៃ" គឺជាការប៉ាន់ស្មង់លំនឹងនៃរបស់នៅក្នុងដៃនីមួយៗ ហើយសំរេចថាតើរបស់មួយណាធ្ងន់ជាង ឬស្រាលជាង។ នេះគឺជាវិធីល្អមួយសំរាប់កុមាររៀបប្រៀបធៀបទម្ងន់នៃរបស់។
- ទម្លាក់របស់ខុសៗគ្នាចូលទៅទឹកក្នុងធុង ឬអាងងូតទឹកដើម្បីមើលរបស់មួយណាដែលបណ្តាលឲ្យទឹកខ្ពាតធំជាងគេ។ និយាយអំពីមូលហេតុដែលរបស់ខ្លះបណ្តាលឲ្យទឹកខ្ពាតធំជាងរបស់ផ្សេងទៀត។
- បង្ហាប់ប្រាប់កូនរបស់លោកអ្នក អំពីរបៀបលោកអ្នកប្រើជញ្ជីងក្នុងចង្ក្រានដាំស្ល ដើម្បីថ្លឹងគ្រឿងផ្សំម្ហូប។
- ឲ្យកូនរបស់លោកអ្នកថ្លឹងទម្ងន់របស់គេនៅពីលើជញ្ជីងនៅក្នុងបន្ទប់ទឹក។ ថ្លឹងទម្ងន់សមាជិកគ្រួសារឯទៀត និងសត្វចិញ្ចឹមផងដែរ។
- និយាយអំពីទម្ងន់របស់កូនលោកអ្នកនៅពេលគេកើតមក។
- បង្ហាញប្រាប់អំពីកន្លែងដែលទម្ងន់នឹងត្រូវបានកត់ទុក នៅពេលទៅផ្សារទិញឥវ៉ាន់។
- ឲ្យកូនរបស់លោកអ្នកជួយលោកអ្នកថ្លឹងរបស់ទាំងឡាយ នៅពេលទៅផ្សារទិញឥវ៉ាន់។
- លេងពីលើក្តារសំរាប់ក្មេងជិះលេង ហើយនិយាយអំពីរបៀបយ៉ាងណាដើម្បីឲ្យក្តារជិះនេះវាឡើងចុះ ឬនៅស្មើគ្នា។